# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៤ អនក្រ/បក

## អនុក្រឹត្យ

## ស្តីពី

## ការចេញផ្សាយក្រដាសប្រាក់ប្រភេទ ១០០ រៀល គំរូថ្មី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបសអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## សំរេច

**មាត្រា ១ .** អនុញ្ញាតអោយចេញផ្សាយ ធ្វើចរាចរនិងប្រើប្រាស់ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា នូវក្រដាសប្រាក់ ១០០ រៀល គំរូថ្មី ទន្ទឹមនឹងប្រភេទប្រាក់ដែលមានចេញផ្សាយរួចមកហើយ ។

**មាត្រា ២ :** ធនាគារជាតិនៃកម្ពុជា មានភារកិច្ចចេញសេចក្តីប្រកាសមួយ ដើម្បីផ្សព្វផ្សាយពីលក្ខណៈសំគាល់ នៃក្រដាសប្រាក់គំរូថ្មីនេះ ។

**មាត្រា ៣** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ននិងអភិបាលខេត្តក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ- កាលប្បវត្តិ*